# ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន

កិច្ចប្រជុំលើកទី 27

ថ្ងៃព្រហស្បតិ៍ ទី 13 ខែសីហា ឆ្នាំ 2026 ម៉ោង 6:30 ល្ងាច

ប្រជុំផ្ទាល់នៅ៖ Stockbridge MA

First Congregational Church

4 Main Street, Stockbridge, MA 01262

# កិច្ចដំណើរការប្រជុំ និងរបៀបវារៈ

# ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន

**កិច្ចប្រជុំលើកទី 27 • ថ្ងៃទី 13 ខែសីហា ឆ្នាំ 2026 • ម៉ោង 6:30 ល្ងាច**

## កិច្ចដំណើរការប្រជុំ

➲ **ការបកប្រែភាសានឹងត្រូវបានផ្តល់ជូនជាភាសា៖ Español, Kreyòl ayisyen, 普通话, Português, Kriolu, Tiếng Việt និងភាសាសញ្ញាអាមេរិក (ASL)**

- ដើម្បីចូលរួមជាភាសាអង់គ្លេស សូមចុចលើរូបសញ្ញា “Interpretation” រួចជ្រើសយកភាសា English ។
- Para entrar no canal em português, clique no ícone “Interpretation” e selecione “Portuguese”
- Pa partisipa na Kriolu, klika na íkone "Intirpretason" y silisiona "Cape Verdean Creole“
- Si alguien desea interpretación en español, haga clic en “Interpretation” y seleccione “Spanish”
- Pou rantre nan chanèl kreyòl ayisyen an, klike sou ikòn “Interpretation” an epi chwazi “Haitian Creole”
- 要以普通话参加会议，请单击口语图标并选择 "Chinese”.
- Để vào kênh bằng tiếng Việt, hãy nhấp vào biểu tượng “Interpretation” và chọn “Vietnamese”.

➲ **សូមនិយាយយឺតៗ។**

➲ **អ្នកចូលរួមទាំងអស់ត្រូវតែជ្រើសរើសបណ្តាញភាសា ទោះបីជាមើលបទបង្ហាញនោះជាភាសាអង់គ្លេសក៏ដោយ។**




➲ **ប្រសិនបើអ្នកចង់បានស្លាយជាទម្រង់ឯកសារបកប្រែ សូមចូលទៅកាន់គេហទំព័រ EJC តាមរយៈ:**
[https://www.mass.gov/service-details/environmental-justice-council-ejc-meetings](https://www.mass.gov/service-details/environmental-justice-council-ejc-meetings)

**កិច្ចប្រជុំនេះកំពុងត្រូវបានថតទុក**

# របៀបវារៈ៖

- ទិដ្ឋភាពទូទៅនៃកិច្ចប្រជុំ កិច្ចដំណើរការប្រជុំ និងរបៀបវារៈ
- ការហៅឈ្មោះសមាជិក និងការអនុម័តលើកំណត់ហេតុប្រជុំ EJC ពីមុន
- មតិយោបល់សាធារណៈ
- មជ្ឈមណ្ឌលទិន្នន័យ
- មតិយោបល់សាធារណៈ (តាមពេលវេលាអនុញ្ញាត)
- ជំហានបន្ទាប់
- ការលើកវារកាល



## ការអនុម័តលើកំណត់ហេតុប្រជុំថ្ងៃទី 11 ខែមិថុនា ឆ្នាំ 2026 និងការហៅឈ្មោះ៖ សមាជិកក្រុមប្រឹក្សា EJ

- Madeline Fraser Cook
- Melissa Harding-Ferretti
- Cheryll Holley
- Caroline Hon
- Lydia Lowe
- Marcos Luna
- Peter Maathey
- María Belén Power
- Sofia Owen
- Jen Salinetti
- Patricia Spence
- Miles Gresham
- Harleen Marwah
- Paula Garcia

## សំណួរ និងមតិយោបល់សាធារណៈ

*សូមកំណត់មតិយោបល់នីមួយៗត្រឹមរយៈពេលពីរនាទី ដើម្បីទុកពេលឱ្យអ្នកដទៃទៀតបញ្ចេញមតិ*

# មជ្ឈមណ្ឌលទិន្នន័យ

## Commonwealth of Massachusetts

### Executive Offices of Economic Development & Energy and Environmental Affairs

# ក្របខ័ណ្ឌមជ្ឈមណ្ឌលទិន្នន័យសម្រាប់ រដ្ឋម៉ាសាឈូសេត

*ខែសីហា 2026*



# ទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌ

- មជ្ឈមណ្ឌលទិន្នន័យអាចពង្រឹង**សេដ្ឋកិច្ចនវានុវត្តន៍ និងការប្រកួតប្រជែងនៃសហធនរដ្ឋ** តាមរយៈការគាំទ្រឧស្សាហកម្មនានាដូចជា **បច្ចេកវិទ្យាជីវៈ ហិរញ្ញវត្ថុ ការការពារ**និង**ការគណនាកម្រិតខ្ពស់**។
- បទពិសោធទូទាំងប្រទេស បង្ហាញថា**អាចធ្វើឱ្យអ្នកបង់ថ្លៃសេវាត្រូវចំណាយ និងមានផលប៉ះពាល់ដល់សហគមន៍** ដូចជា៖
  - ការកើនតម្លៃថាមពល និងប្រព័ន្ធមានភាពតឹងតែង
  - ភាពតឹងតែងលើហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី និងទឹក
  - ផលប៉ះពាល់ដល់គុណភាពខ្យល់ និងសុខភាពសាធារណៈ
  - វិវាទសំឡេងរំខាន និងការប្រើប្រាស់ដីធ្លី
- ក្របខ័ណ្ឌដែលបានចេញផ្សាយនៅថ្ងៃទី 25 ខែមិថុនា បង្កើត**ការរំពឹងទុកច្បាស់លាស់សម្រាប់ការអភិវឌ្ឍមជ្ឈមណ្ឌលទិន្នន័យដែលមានទំនួលខុសត្រូវ**។
- បណ្ដាគម្រោងដែលស្វែងរកការលើកទឹកចិត្តពន្ធពីរដ្ឋត្រូវតែបង្ហាញថាពួកគេនឹង៖
  - ផ្ដល់មូលនិធិដល់ហេដ្ឋារចនាសម្ព័ន្ធដែលពួកគេត្រូវការ
  - នាំយកមកនូវថាមពលស្អាតផ្ទាល់ខ្លួន
  - ការពារបរិស្ថាន និងធនធានសហគមន៍ និង
  - ផ្ដល់អត្ថប្រយោជន៍សាធារណៈដែលអាចវាស់វែងបាន។
- ក្របខ័ណ្ឌនេះក៏**ណែនាំបណ្ដាទីភ្នាក់ងាររដ្ឋ សាលាក្រុង និងអ្នកបង្កើតគោលនយោបាយ** ព្រមទាំងបំពេញបន្ថែមលើលក្ខខណ្ឌតម្រូវលិខិតអនុញ្ញាត និងបទប្បញ្ញត្តិដែលមានស្រាប់ផងដែរ។

# រដ្ឋម៉ាសាឈូសេត និងអភិបាលកិច្ចមជ្ឈមណ្ឌលទិន្នន័យ

**6.25.2026 សេចក្តីថ្លែងការណ៍ការរំពឹងទុករបស់រដ្ឋបាល Healey-Driscoll សម្រាប់មជ្ឈមណ្ឌលទិន្នន័យដែលមានទំនួលខុសត្រូវ**

*អភិបាល Healey បានផ្អាកការទទួលពាក្យសុំលើកលែងពន្ធលើការលក់ថ្មីៗរហូតទាល់តែមានការការពាររឹងមាំជាងនេះ ដើម្បីធានាថាគម្រោងនានាមិនបង្កើនបន្ទុក និងតម្លៃថាមពល ឬបង្កគ្រោះថ្នាក់ដល់សហគមន៍ និងបរិស្ថាន។*

រដ្ឋម៉ាសាឈូសេតកំពុងបង្កើតក្របខ័ណ្ឌមួយក្នុងចំណោមក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយបំផុតសម្រាប់ការអភិវឌ្ឍ និងប្រតិបត្តិការមជ្ឈមណ្ឌលទិន្នន័យ។

គម្រោងត្រូវតែបង្ហាញថា ពួកវាអាចទ្រទ្រង់ដល់ការប្រកួតប្រជែងខាងនវានុវត្តន៍ និងសេដ្ឋកិច្ចដោយមិនបង្កើនការចំណាយ ដល់អ្នកបង់ថ្លៃសេវា ធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធមានភាពតឹងតែង ឬបង្កគ្រោះថ្នាក់ដល់សហគមន៍ ឬបរិស្ថាន។

ការលើកទឹកចិត្តសាធារណៈនឹងត្រូវបានបម្រុងទុកសម្រាប់គម្រោងដែលបំពេញតាមការរំពឹងទុកទាំងនេះ និងផ្តល់អត្ថប្រយោជន៍សាធារណៈច្បាស់លាស់។

# គោលការណ៍នៃក្របខ័ណ្ឌមជ្ឈមណ្ឌលទិន្នន័យ

1. គ្មានការផ្លាស់ប្តូរការចំណាយលើថាមពល បណ្តាញអគ្គិសនី ទឹក ឬការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចំពោះអ្នកបង់ថ្លៃសេវា ឬអ្នកបង់ពន្ធ។
2. ការផ្គត់ផ្គង់ថាមពលស្អាតបំពេញតាមតម្រូវការ។
3. រក្សាភាពគួរឱ្យទុកចិត្តនៃបណ្តាញអគ្គិសនី ដោយមិនបង្កើនការកកស្ទះ ឬការចំណាយលើហេដ្ឋារចនាសម្ព័ន្ធដែលគាំងដំណើរការ។
4. ការពារសហគមន៍ពីផលប៉ះពាល់បរិស្ថាន សុខភាព និង
ហេដ្ឋារចនាសម្ព័ន្ធ។
5. ប្រើទឹកដោយភាពទទួលខុសត្រូវដោយមិនប៉ះពាល់ដល់ការផ្គត់ផ្គង់ ឬគុណភាពនៅក្នុងមូលដ្ឋាន។
6. ផ្តល់ការងារដែលមានគុណភាព ការវិនិយោគក្នុងមូលដ្ឋាន និងការប្រកួតប្រជែងសេដ្ឋកិច្ច។
7. ធ្វើប្រតិបត្តិការដោយតម្លាភាព។

June 25, 2026

**HEALEY-DRISCOLL ADMINISTRATION STATEMENT OF EXPECTATIONS FOR RESPONSIBLE DATA CENTER DEVELOPMENT AND OPERATIONS IN MASSACHUSETTS**

*Guidance for data centers seeking sales and use tax exemptions and expectations for broader data center development*

**OVERVIEW**

Data centers present significant economic development opportunities for Massachusetts, including the creation of construction jobs, increased local property tax revenue, and investments in supporting infrastructure. They can also strengthen the Commonwealth's innovation economy by improving digital infrastructure and reducing latency for industries such as biotechnology, finance, defense, and advanced computing. In addition, New England's climate can provide natural efficiency advantages for these energy-intensive facilities.

At the same time, experience from across the country demonstrates that large-scale data center development can create challenges if not carefully planned and managed. Data centers require substantial investments in electric grid infrastructure and power generation resources, which can affect energy affordability and reliability for all energy consumers. Their development also raises climate, environmental, public health, and community concerns, including potential impacts on air quality, water resources, noise levels, and local land use.

Governor Healey's framework establishes principles and expectations for responsible data center development in Massachusetts that balances economic growth and innovation with protections for Massachusetts residents, businesses, and communities.

The framework is intended to provide clarity for data center developers considering projects in Massachusetts on responsible practices, and explicit expectations for those seeking the sales and use tax exemption under Massachusetts law (M.G.L. c. 64H, § 6(zz)). The framework will also be used to guide: (1) executive agencies and municipalities evaluating data center proposals; (2) discussions of executive agencies with the Legislature, municipalities, and others on data center policy; and (3) actions by the Department of Public Utilities (DPU) within its existing authority, including implementation of Executive Order 654.

This framework also supplements, and does not replace, existing state and local siting, permitting, and regulatory requirements. These include, among others: Energy Facilities Siting Board requirements for onsite generation facilities exceeding 25 MW (M.G.L. c.

| ការរំពឹងទុក | សេចក្តីលម្អិតនៃលក្ខខណ្ឌតម្រូវ |
|---|---|
| 1. ការផ្គត់ផ្គង់ថាមពល (“នាំយកមកនូវថាមពលស្អាតផ្ទាល់ខ្លួន”) | • ផ្តល់ ឬទិញថាមពលស្អាតគ្រប់គ្រាន់ដោយផ្ទាល់ ដើម្បីបំពេញតាមតម្រូវការរបស់ទីតាំង ដោយផ្តល់អាទិភាពលើថាមពលស្អាតនៅនឹងកន្លែង ដែលអាចធ្វើទៅបាន។<br>• បង្កើនល្បឿនការអភិវឌ្ឍថាមពលស្អាតថ្មី ជាជាងប្រកួតប្រជែងដណ្តើមធនធានដែលមានស្រាប់។<br>• ការពារអ្នកបង់ថ្លៃសេវាពីថ្លៃចំណាយដែលទាក់ទងនឹងការកើនឡើងនៃបន្ទុកថាមពលថ្មី។ |
| 2. ប្រសិទ្ធភាពថាមពល ភាពបត់បែននៃបណ្តាញអគ្គិសនី និងការបង្កើនប្រសិទ្ធភាពប្រព័ន្ធ | • ប្រើស្តង់ដារប្រសិទ្ធភាពឈានមុខគេក្នុងវិស័យ។<br>• ចូលរួមកម្មវិធីឆ្លើយតបនឹងតម្រូវការ និងភាពបត់បែននៃបន្ទុកថាមពល។<br>• ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ កន្លែងស្តុកទុក និងឧបករណ៍គ្រប់គ្រងថាមពលកម្រិតខ្ពស់ ដែលទ្រទ្រង់បណ្តាញអគ្គិសនីខ្នាតតូច បណ្តាញកម្តៅក្នុងផែនដី និងរោងចក្រថាមពលនិម្មិត នៅកន្លែងដែលអាចធ្វើទៅបាន។ |
| 3. គុណភាពខ្យល់ និងសុខភាពសាធារណៈ | • កាត់បន្ថយការបំភាយឧស្ម័ន និងសំឡេងរំខានឱ្យដល់កម្រិតអប្បបរមា។<br>• បន្ថយការពឹងផ្អែកលើការបង្កើតថាមពលបម្រុងដោយប្រើម៉ាស៊ូត នៅកន្លែងដែលអាចធ្វើទៅបាន។<br>• ផ្តោតការយកចិត្តទុកដាក់លើការកាត់បន្ថយផលប៉ះពាល់លើសហគមន៍យុត្តិធម៌បរិស្ថាន។ |
| 4. ការប្រើប្រាស់ទឹក និងការការពារហេដ្ឋារចនាសម្ព័ន្ធ | • បង្ហាញពីលទ្ធភាពផ្គត់ផ្គង់ទឹកប្រកបដោយចីរភាព និងផ្តល់មូលនិធិសម្រាប់ការកែលម្អហេដ្ឋារចនាសម្ព័ន្ធទឹក និងសំណល់រាវដែលចាំបាច់។<br>• បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក និងការប្រើប្រាស់ទឹកឡើងវិញឱ្យដល់កម្រិតអតិបរមា។<br>• ការពារគុណភាពទឹកស្របតាមស្តង់ដារ និងលក្ខខណ្ឌតម្រូវរបស់រដ្ឋម៉ាសាឈូសេត។ |
| 5. ការអនុវត្តពលកម្មដែលមានទំនួលខុសត្រូវ និងការបង្កើតការងារ | • បង្កើតការងារសំណង់ដែលមានគុណភាពខ្ពស់ និងអចិន្ត្រៃយ៍ ដោយប្រើកិច្ចព្រមព្រៀងពលកម្មគម្រោង ឬកិច្ចព្រមព្រៀងសន្តិភាពពលកម្ម។<br>• គាំទ្រការជួលកម្លាំងពលកម្មក្នុងមូលដ្ឋាន ការបណ្តុះបណ្តាល និងការហ្វឹកហ្វឺនជំនាញដែលបានចុះបញ្ជី។<br>• ផ្តល់លក្ខខណ្ឌការងារដែលមានសុវត្ថិភាព និងប្រាក់ឈ្នួលដែលមានភាពប្រកួតប្រជែង។ |
| 6. អត្ថប្រយោជន៍ និងការចូលរួមរបស់<br>សហគមន៍ | • ស្វែងរកការចូលរួមពីសហគមន៍ពីដំបូង និងពេញរយៈពេលអភិវឌ្ឍន៍ ដោយមានគោលបំណងផ្តល់អត្ថប្រយោជន៍ជាក់ស្តែងលើសពីការកាត់បន្ថយគ្រោះថ្នាក់ដែលតម្រូវឱ្យធ្វើ។<br>• បង្កើតផែនការ និងកិច្ចព្រមព្រៀងអត្ថប្រយោជន៍សហគមន៍ដែលស្របនឹងផែនការ និងកិច្ចព្រមព្រៀងដែលបានបង្កើតដោយការិយាល័យសមធម៌ និងយុត្តិធម៌បរិស្ថាន។<br>• ចៀសវាងការបង្កើនបន្ទុកលើសហគមន៍ដែលទន់ខ្សោយ និងការប្រើប្រាស់ MassEnviroScreen ដើម្បីវាយតម្លៃគម្រោង និងផលប៉ះពាល់សរុបដែលអាចកើតមាន។ |
| 7. នវានុវត្តន៍ និងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងមូលដ្ឋាន | • បង្កើតតម្លៃសេដ្ឋកិច្ចយូរអង្វែងលើសពីការសាងសង់។<br>• ពង្រឹងសេដ្ឋកិច្ចនវានុវត្តន៍នៃរដ្ឋម៉ាសាឈូសេត។<br>• ផ្តល់អាទិភាពដល់អ្នកផ្គត់ផ្គង់នៅក្នុងរដ្ឋម៉ាសាឈូសេត។<br>• ពិចារណាលើការប្រើប្រាស់ដីដែលមានការប្រកួតប្រជែង និងកាត់បន្ថយការបាត់បង់ឱកាស។ |
| 8. តម្លាភាពនៃគម្រោង | • បិទផ្សាយជាសាធារណៈនូវទំហំគម្រោង ផែនការពង្រីក ការប្រើប្រាស់ថាមពលនិងទឹក ព័ត៌មានទាក់ទងនឹងការបំភាយឧស្ម័ន សារធាតុគ្រោះថ្នាក់ ឱកាសខ្សែសង្វាក់ផ្គត់ផ្គង់ និងការផ្ទៀងផ្ទាត់ឯករាជ្យ។ |

# ការអនុវត្ត និងជំហានបន្ទាប់

- ទីភ្នាក់ងាររដ្ឋ និងទីភ្នាក់ងារបញ្ញត្តិកម្មត្រូវបានរំពឹងថានឹងកំណត់ពីរបៀបដែលក្របខ័ណ្ឌនេះអាចអនុវត្តនៅក្នុងដែនសមត្ថកិច្ចដែលមានស្រាប់។
- ស្វែងរកដែនសមត្ថកិច្ចផ្នែកនីតិប្បញ្ញត្តិបន្ថែមដើម្បីឱ្យមានលក្ខខណ្ឌលើការលក់ និងការលើកលែងពន្ធប្រើប្រាស់។
- បង្កើតឯកសារណែនាំ ដើម្បីជួយសាលាក្រុងក្នុងការវាយតម្លៃមជ្ឈមណ្ឌលទិន្នន័យដែលបានស្នើ។




Executive Office of Energy and Environmental Affairs
មានសំណួរទេ?
Willard Brook State Forest

# សំណួរ និងមតិយោបល់សាធារណៈ

*សូមកំណត់មតិយោបល់នីមួយៗត្រឹមរយៈពេលពីរនាទី ដើម្បីទុកពេលឱ្យអ្នកដទៃទៀតបញ្ចេញមតិ*




## ជំហានបន្ទាប់ និងការលើកវារកាល

កាលបរិច្ឆេទប្រជុំបន្ទាប់៖

- ថ្ងៃទី 8 ខែតុលា

ព័ត៌មានអំពី EJC និងទីតាំងប្រជុំអាចរកឃើញនៅក្នុងតំណ
https://www.mass.gov/orgs/environmental-justice-council-ejc

ត្រូវស្នើសុំការបកប្រែផ្ទាល់នៃភាសាសញ្ញា ASL បីសប្តាហ៍មុនការប្រជុំតាមអ៊ីមែល
meetings@erg.com